ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៥៥

ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩

សាលដីកា

លេខ ៨២ IV

ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

# សាលដីកា

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជាសាធារណៈ ពិភាក្សាដេញដោល ស្តាប់សេចក្តីសន្និដ្ឋានភាគីពាក់ព័ន្ធ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ដោយអង្គជំនុំជម្រះដែលមានសមាសភាពចៅក្រមដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.លោក [redacted] ជាចៅក្រម

៣.លោក [redacted] ជាចៅក្រម

៤.លោក [redacted] ជាចៅក្រម

៥.លោក [redacted] ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted]

**តំណាងមហាអយ្យការ**

-ឯកឧត្តម [redacted] បាន:ជាអគ្គព្រះរាជអាជ្ញារង

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៨៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឆៃ, ឈ្មោះ [redacted] ពិសិដ្ឋ, ឈ្មោះ [redacted] ច័ន្ទដារ៉ា ដែលធ្វើឡើងតាមរយៈលោក [redacted] សុភ័ស្ត ជាមេធាវីតំណាងក្នុងការប្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៣ក្រII “រ” ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

បុគ្គលប្តឹងសាទុក្ខ ៖

១.ជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់ឆៃ** ភេទប្រុស កើតឆ្នាំ១៩៨៦ សញ្ជាតិខ្មែរ មុខរបរជាកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ [redacted] “រ” នៅលីវ។

មានលោកមេធាវី [redacted] **សុភ័ស្ត** ជាអ្នកការពារ។



Scanned with CamScanner

២.ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ហៅ ឆាង ភេទប្រុស កើតឆ្នាំ១៩៩៩ សញ្ជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។ នៅលីវ។

មានលោកមេធាវី [redacted] សុភ័ស្ត ជាអ្នកការពារ។

៣.ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា ភេទប្រុស កើតឆ្នាំ២០០០ សញ្ជាតិខ្មែរ មុខរបរសិស្សថ្នាក់ទី១២ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តតាកែវ កំរិតវប្បធម៌ថ្នាក់ទី ១២ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ"។ នៅលីវ ។ ជានីតិជន ។ ទោសពីមុនគ្មាន។

មានលោកមេធាវី [redacted] សុភ័ស្ត ជាអ្នកការពារ។

បុគ្គលមិនប្តឹងសាទុក្ខ ៖

១.ជនជាប់ចោទឈ្មោះ [redacted] រដ្ឋា ហៅ គ្រិច ភេទប្រុស អាយុ ៣០ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាកម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ កំរិតវប្បធម៌ថ្នាក់ទី ៧ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" មានកូនម្នាក់ ។ ជានីតិជន។ ទោសពីមុនគ្មាន។

២.ជនជាប់ចោទឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២៧ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។ ជានីតិជន ។ ទោសពីមុនគ្មាន។ (គេចខ្លួន)

៣.ជនជាប់ចោទឈ្មោះ [redacted] ចាន់ដារ៉ា ភេទប្រុស អាយុ ២៣ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ កាន់សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ។ នៅលីវ។ ជានីតិជន ។ ទោសពីមុនគ្មាន។ (គេចខ្លួន)

៤.ជនជាប់ចោទឈ្មោះ [redacted] សាវ័ន ហៅ តាវ័ន ភេទប្រុស អាយុ ៥៧ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ស្ពឺ សាសនាព្រះពុទ្ធ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០៤ នាក់ ។ ជានីតិជន ។ ទោសពីមុនគ្មាន។ (គេចខ្លួន)



Scanned with CamScanner

ជាប់ចោទពីបទរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិត្រពាំងក្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ បទល្មើសដែលមានចែងនិងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ១៧ និង៣៥ នាទី កម្លាំងនគរបាលការិយាល័យអន្តរាគមន៍ (ក៨) នៃមន្ទីរប្រឆាំងគ្រឿងញៀន សហការជាមួយសមត្ថកិច្ចនគរបាលខេត្តតាកែវ បានចុះបង្ក្រាបករណីរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នៅភូមិត្រពាំងក្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ និងបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ផៃ ភេទប្រុស អាយុ ២២ ឆ្នាំ , ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៩ ឆ្នាំ, ឈ្មោះ [redacted] ច័ន្ទដារ៉ា ភេទប្រុស អាយុ ១៨ ឆ្នាំ និងឈ្មោះ [redacted] វឌ្ឍា ភេទប្រុស អាយុ ៣០ ឆ្នាំ ហើយដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីនអាយ (ម៉ាទឹកកក) ទម្ងន់ ៥១,៨០ ក្រាម, ម៉ូតូចំនួន ០២ គ្រឿង, ទូរស័ព្ទចំនួន០៤គ្រឿង, ជញ្ជីងថ្លឹងថ្នាំញៀន ០១ គ្រឿង។ លុះដល់ម៉ោង ២០ និង ៣០ នាទី ថ្ងៃខែដដែល សមត្ថកិច្ចបានពន្លាតដែនដីដើម្បីបន្តឆែកឆេរលំនៅដ្ឋានរបស់ឈ្មោះ [redacted] សាវ៉ន ហៅ តាវ៉ន ភេទប្រុស អាយុ ៥៧ ឆ្នាំ នៅភូមិត្រពាំងខ្យង ឃុំទួលអំពិល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ហើយដកហូតបានថ្នាំញៀនប្រភេទមេតំហ្វេតាមីនអាយ (ម៉ាទឹកកក) ទម្ងន់ ៧៦,៨០ ក្រាម, ស្លាកលេខម៉ូតូចំនួន ០២, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួន ០៤, ជញ្ជីងថ្លឹងថ្នាំញៀន ០១ គ្រឿង។ លុះដល់វេលាម៉ោង ២១ និង ២០ នាទី សមត្ថកិច្ចបានបន្តឆែកឆេរលំនៅដ្ឋានរបស់ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២៧ ឆ្នាំ នៅភូមិដំណាក់ត្រាចឃុំទួលអំពិល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដោយដកហូតបានម៉ូតូចំនួន ០២ គ្រឿង, កុំព្យូទ័រម៉ាក Dell (ដេល) មួយគ្រឿង និងសំបុត្របញ្ជាក់កំណើតមួយសន្លឹក រួចកសាងសំណុំរឿងបញ្ជូនមកតុលាការ។ ដោយឡែកជនជាប់ចោទឈ្មោះ [redacted] ចាន់ដារ៉ា, ឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] សាវ៉ន បានរត់គេចខ្លួនតែមានសាវតាជាតិគ្រប់គ្រាន់ ហើយចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវបានចេញដីកាចាប់ខ្លួនរួចហើយ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១០៧ (ក) ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ឱ្យរួចខ្លួនពីបទចោទលើឈ្មោះ ៖

ក.ឈ្មោះ [redacted] វ៉ាន់ផៃ ភេទប្រុស អាយុ ២២ ឆ្នាំ (មានសាវតាជាតិខាងលើ)

ខ.ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៨ ឆ្នាំ (មានសាវតាជាតិខាងលើ)



Scanned with CamScanner

គ.ឈ្មោះ [redacted] ច័ន្ទដារ៉ា ភេទប្រុស អាយុ ១៨ ឆ្នាំ (មានសាវតាជាតិខាងលើ)

ពីបទជួញដូរសារធាតុញៀនដោយខុសច្បាប់ ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.ផ្តន្ទាទោស ៖

ក.ឈ្មោះ [redacted] វ៉ាន់ឆៃ ភេទប្រុស អាយុ ២២ ឆ្នាំ (មានសាវតាជាតិខាងលើ)

ខ.ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ១៨ ឆ្នាំ (មានសាវតាជាតិខាងលើ)

គ.ឈ្មោះ [redacted] ច័ន្ទដារ៉ា ភេទប្រុស អាយុ ១៨ ឆ្នាំ (មានសាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ។

ពីបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ឃ.ឈ្មោះ [redacted] រដ្ឋា ភេទប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ (សាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ។

ពីបទជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ង.ឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២៧ ឆ្នាំ ជាតិខ្មែរ (សាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន។

ច.ឈ្មោះ [redacted] ចាន់ដារ៉ា ភេទប្រុស អាយុ ២៣ ឆ្នាំ ជាតិខ្មែរ (សាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន។

ឆ.ឈ្មោះ [redacted] សាវ៉ន ភេទប្រុស អាយុ ៥៧ ឆ្នាំ ជាតិខ្មែរ (សាវតាជាតិខាងលើ)

-ដាក់ពន្ធនាគារកំណត់រយៈពេល ០៧ (ប្រាំពីរ) ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន។

ពីបទជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុចទី៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឃុំខ្លួនឈ្មោះ [redacted] កុសល ភេទប្រុស អាយុ ២៧ ឆ្នាំ ឈ្មោះ [redacted] ចាន់ដារ៉ា ភេទប្រុស អាយុ ២៣ ឆ្នាំ និងឈ្មោះ [redacted] សាវ៉ន ភេទប្រុស អាយុ ៥៧ ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៤.វត្ថុតាងរួមមាន

ក.សារធាតុញៀនប្រភេទមេតំហ្វេតាមីនអាយ (ម៉ាទឹកកក) របស់ឈ្មោះ [redacted] ចាន់ដារ៉ា ទម្ងន់ ៥១,៨០ ក្រាម, របស់ឈ្មោះ [redacted] សារ៉ន ទម្ងន់ ៧៦,៨០ ក្រាម។ ទម្ងន់សរុប ១២៨,៦០ ក្រាម ទូរស័ព្ទដៃម៉ាកអ៊ិនចុចពិលចាស់ៗ (ខូច) ចំនួនសរុប ០៤ គ្រឿង និងជញ្ជីងថ្លឹងថ្នាំញៀនចំនួនសរុប ០២ គ្រឿង, ស្លាកលេខម៉ូតូចំនួនពីរ លេខភ្នំពេញ ១FV-០៤៨១ ត្រូវរឹបអូស និងបំផ្លាញចោល តាមមាត្រា ៨៤ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ.ម៉ូតូចំនួន ០៤ គ្រឿង៖ ទី១- ម៉ាកនិច ពណ៌ស គ្មានស្លាកលេខ, ទី២- ម៉ាក SL ពណ៌បៃតងចាស់ ពាក់ស្លាកលេខ តាកែវ ១IN-០៦៦២, ទី៣- ម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅពាក់ស្លាកលេខភ្នំពេញ ១GR-៥៩៥០ និងទី៤- ម៉ាកហុងដាសេ ១២៥ ពណ៌ព្រីងទុំ ពាក់ស្លាកលេខសៀមរាប ១L-២៥៩៦ និងម៉ាស៊ីនកុំព្យូទ័រមួយគ្រឿង ម៉ាក Dell (ដេល) ពណ៌ខ្មៅ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ តាមមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

គ.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួន ០៤ សន្លឹក និងសំបុត្របញ្ជាក់កំណើតចំនួន ០២ សន្លឹក ត្រូវប្រគល់ឱ្យទៅម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឆៃ , ឈ្មោះ [redacted] ពិសិដ្ឋ ,ឈ្មោះ [redacted] ច័ន្ទដារ៉ា និងឈ្មោះ [redacted] រដ្ឋា។ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] កុសល, ឈ្មោះ [redacted] ចាន់ដារ៉ា និងឈ្មោះ [redacted] សារ៉ន ទុកសិទ្ធិឱ្យប្តឹងទាស់និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦០ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់លោក [redacted] ចាន់តារា ឋានៈជាព្រះរាជអាជ្ញាអមសាលាដំបូងខេត្តតាកែវ ប្តឹងឧទ្ធរណ៍មិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ១០៧ (ក) ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តតាកែវ ត្រង់ចំណុចដែលសម្រេចឱ្យជនជាប់ចោទ ១-ឈ្មោះ [redacted] វ៉ាន់ឆៃ, ២-ឈ្មោះ [redacted] ពិសិដ្ឋ, ៣- [redacted] ច័ន្ទដារ៉ា រួចផុតពីបទចោទពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តតាកែវ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។



Scanned with CamScanner

២.បដិសេធចំណុចទី ១ នៃសាលក្រមព្រហ្មទណ្ឌលេខ ១០៧ "ក" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តតាកែវ ចោលជាអសារបង់។

៣.ផ្តន្ទាទោស

ក.ឈ្មោះ [redacted] វ៉ាន់ឆៃ

ខ.ឈ្មោះ [redacted] ពិសិដ្ឋ

គ.ឈ្មោះ [redacted] ច័ន្ទដារ៉ា

ដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈ ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ កំណត់ ១០.០០០.០០០៛ (ដប់លាន) រៀល។

ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ ។ បទល្មើសព្រហ្មទណ្ឌមានចែងនិងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៥.សាលដីកានេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩។

-បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ១៨៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ឆៃ, ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ច័ន្ទដារ៉ា ដែលធ្វើឡើងតាមរយៈលោក [redacted] សុភ័ស្ត ជាមេធាវីតំណាងក្នុងការប្តឹងសាទុក្ខ ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍សម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។ តំណាងមហាអយ្យការឯកភាពក្នុងការយល់ឃើញ និងការសម្រេចរបស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍។ ដូចនេះ បណ្តឹងសាទុក្ខរបស់លោកមេធាវី [redacted] សុភ័ស្ត ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា, [redacted] វ៉ាន់ឆៃ, [redacted] ពិសិដ្ឋ មិនមានមូលហេតុដូច



Scanned with CamScanner

ក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីឡើយ។ ហេតុដូច្នេះ តំណាងមហាអយ្យការប្ដឹងសុំចំពោះតុលាការកំពូលឱ្យ ៖

១.ទទួលបណ្ដឹងសាទុក្ខលេខ ១៨៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់លោក [redacted] សុភ័ស្ត ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា, [redacted] វ៉ាន់ផៃ, [redacted] ពិសិដ្ឋ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រII "វ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ផៃ បានឆ្លើយថា ខ្លួនកើតនៅឆ្នាំ១៩៩៦។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយថា ខ្លួនឈ្មោះ [redacted] ពិសិដ្ឋ ហៅ ឆាង កើតនៅឆ្នាំ១៩៩៩។

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា បានឆ្លើយថា ខ្លួនកើតនៅឆ្នាំ ២០០០ ឪពុករបស់ខ្លួនមានឈ្មោះ [redacted] ហើយម្ដាយឈ្មោះ [redacted]។

-លោក [redacted] សុភ័ស្ត ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ផៃ, ឈ្មោះ [redacted] ពិសិដ្ឋ, ឈ្មោះ [redacted] ច័ន្ទដារ៉ា បានធ្វើសេចក្ដីសន្និដ្ឋានថា កូនក្ដីខ្លួនទាំងបីនាក់បានប្ដឹងសាទុក្ខមកតុលាការកំពូល ដោយសារតែកូនក្ដីខ្លួនមិនបានទាន់បានប្រើប្រាស់ផង ស្រាប់តែសមត្ថកិច្ចមកចាប់ខ្លួនតែម្ដង តែឈ្មោះ [redacted] ច័ន្ទដារ៉ា ហៅ [redacted] ទេ ជាអ្នកជួញដូរថ្នាំញៀននោះ។ កូនក្ដីខ្លួនបានទៅទិញយកមកប្រើប្រាស់តែប៉ុណ្ណោះ មិនបានជួញដូរនោះទេ។ ខ្លួនសំណូមសុំឱ្យតុលាការកំពូលមេត្តាបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញ។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាន់ផៃ បានឆ្លើយបន្ថែមថា ខ្លួនសំណូមសុំឱ្យតុលាការកំពូលមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនគ្រាន់តែជាអ្នកប្រើប្រាស់ទេ មិនបានជួញដូរឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយបន្ថែមថា ខ្លួនសំណូម សុំឱ្យតុលាការកំពូលមេត្តាជួយបន្ធូរបន្ថយទោសនិងលើកលែងការចោទប្រកាន់លើខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា បានឆ្លើយបន្ថែមថា ខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាជួយតម្កល់សាលក្រមសាលាដំបូងឱ្យខ្លួនផង។

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានបន្ថែមថា ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា ទើបតែមានអាយុ ១៧ ឆ្នាំជាង ប៉ុណ្ណោះ បើយោងតាមសំបុត្រកំណើត ដូច្នេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាមេត្តាពិចារណាទៅលើអាយុរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា និងសុំក្រុមប្រឹក្សាមេត្តាសម្រេចតាមច្បាប់។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៨៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី [redacted] សុភ័ស្ត ជាអ្នកតំណាងឱ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា ,ឈ្មោះ [redacted] វ៉ាន់អៃ និងឈ្មោះ [redacted] ពិសិដ្ឋ ក្នុងការប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨, មាត្រា ៤២០ និងមាត្រា ៤២២ ត្រង់កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វ៉ាន់អៃ ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ច័ន្ទដារ៉ា ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០៦(ប្រាំមួយ) ឆ្នាំ និងពិន័យជា ប្រាក់ក្នុងម្នាក់ៗកំណត់ ១០.០០០.០០០ (ដប់លាន)រៀល ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងត្របែក ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ តាមមាត្រា ៤០ នៃច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀននោះ តុលាការកំពូលពិនិត្យឃើញថា ការផ្តន្ទាទោសលើជនជាប់ចោទទាំង ៣ នាក់ ដាក់ពន្ធនាគារ និងពិន័យជាប្រាក់នោះ គឺជាការត្រឹមត្រូវតាមច្បាប់ និងមានសំអាងហេតុអំពីមូលដ្ឋានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទហើយ ។ ប៉ុន្តែសាលាឧទ្ធរណ៍គប្បីពិចារណាឡើងវិញត្រង់កាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទទាំង ៣ នាក់ "*នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨*" ពីព្រោះថា តាមកាលបរិច្ឆេទនេះ សាលាឧទ្ធរណ៍ពុំបានសំអាងលើឯកសារភស្តុតាងជាមូលដ្ឋាននោះទេ។ ផ្ទុយទៅវិញតាមសំអាងហេតុរបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ កថាខណ្ឌទី២ ក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍សំអាងហេតុថា តាមការពិនិត្យលើសារណាការពារលើបណ្តឹងឧទ្ធរណ៍លេខ ៧៨១ អ.ក/១៨ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨



Scanned with CamScanner

របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ និងរបាយការណ៍លេខ ២៦/១៨ រ.ប.ក ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨ របស់ស្នងការដ្ឋាននគរបាលខេត្តតាកែវ បានបញ្ជាក់អំពីកាលបរិច្ឆេទនៃការប្រតិបត្តិការរបស់សមត្ថកិច្ច និងការឃាត់ខ្លួនជនសង្ស័យទាំងបីនាក់ ជាក់ស្តែងធ្វើឡើងនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ១៧ និង ៣០ នាទី ជាការត្រឹមត្រូវទៅវិញ។ ម្យ៉ាងទៀតនាពេលសវនាការនៅតុលាការកំពូល ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា បានឆ្លើយថា នៅថ្ងៃកើតហេតុ ហើយចោទប្រកាន់មក លើខ្លួននោះ ខ្លួនមិនទាន់គ្រប់អាយុ ១៨ ឆ្នាំនៅឡើយទេ។ ផ្អែកតាមសំបុត្របញ្ជាក់កំណើតរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា លេខ ១៨១៩ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៦ ចេញដោយមេឃុំខ្វាវ បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា មានថ្ងៃ ខែ ឆ្នាំកំណើត៖ ថ្ងៃសុក្រ ទី០៥ ខែឧសភា ឆ្នាំ២០០០ ដែលគប្បីសាលាឧទ្ធរណ៍ពិនិត្យពិចារណាលើកាលបរិច្ឆេទនៃថ្ងៃ ខែ ឆ្នាំកំណើត របស់បុគ្គលរូបនេះ ដោយធៀបទៅនឹងកាលបរិច្ឆេទនៃអង្គហេតុបទល្មើសដែលបានចោទប្រកាន់ ដើម្បីឈានដល់ការសម្រេចសេចក្តីឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិច្បាប់និងយុត្តិធម៌។

៣-យល់ឃើញថា ផ្នែកខ្លះនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មានមូលហេតុត្រឹមត្រូវតាមបទប្បញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រ II " រ " ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ ត្រឹមត្រូវផ្នែកខ្លះ និងខុសផ្នែកខ្លះ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ១៨៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវីលោក [redacted] សុភ័ស្ត ជាអ្នកតំណាងឲ្យជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា , ឈ្មោះ [redacted] វ៉ាន់ឆៃ និងឈ្មោះ [redacted] ពិសិដ្ឋ ក្នុងការប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រII "រ" ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

២-បដិសេធចំណុច "កាលបរិច្ឆេទនៃហេតុការណ៍បទល្មើស ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ និងអាយុរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទដារ៉ា នៅខណៈពេលពាក់ព័ន្ធនឹងបទល្មើដែលទទួលរងការចោទប្រកាន់នេះ"។



Scanned with CamScanner

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១៥៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជម្រះជាថ្មី លើចំណុចដែលត្រូវបានបដិសេធចោល ដូចមានលើក បង្ហាញក្នុងចំណុចទី ២ ខាងលើនេះ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២០ និងប្រកាសនា សវនាការជាសាធារណៈនៅថ្ងៃសុក្រ ទី២៧ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner